# មេរៀនទី ១៤៩: ស្ដេចយ៉ូសៀសសន្យាថាដើរតាមព្រះជាម្ចាស់

## ២ របាក្សត្រ ៣៤

| |
|---|
| **គោលបំណង៖** ព្រះមានបន្ទូលមកកាន់យើងតាមរយៈព្រះគម្ពីរ។ |

| |
|---|
| **ខគម្ពីរចងចាំ៖ ទំនុកដំកើង ១១៩:១០៥** *"ព្រះបន្ទូលនៃទ្រង់ជាចង្កៀងដល់ជើងទូលបង្គំហើយជា ពន្លឺបំភ្លឺផ្លូវទូលបង្គំផង។"* |

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**

បើយើងគ្មានព្រះយេស៊ូវ តើយើងនឹងនៅទីណា? ទ្រង់គឺជាព្រះបន្ទូលដែលបានក្លាយជាសាច់ឈាម ហើយទ្រង់ជួយឲ្យយើងរស់នៅក្នុងជីវិតដែលគោរពតាមច្បាប់របស់ព្រះ។ ការអានព្រះគម្ពីរ និងការអធិស្ឋាន គឺជាកន្លែងសំខាន់ក្នុងការរីកចម្រើន និងអភិវឌ្ឍខាងព្រលឹងជាគ្រិស្តបរិស័ទ។ ពិចារណាលើចំណុចនេះ៖ តើការថ្វាយបង្គំសំរាប់ជីវិតផ្ទាល់ខ្លួនរបស់អ្នកយ៉ាងណាដែរ? តើមានអ្វីដែលជាការល្អអំពីការថ្វាយបង្គំនេះ? តើអ្វីដែលត្រូវផ្លាស់ប្ដូរ? ព្រះទ្រង់មានព្រះហឫទ័យចង់បង្ហាញដល់អ្នកជាច្រើន។ មិនថាអ្នកនឹងធ្វើអ្វីនៅថ្ងៃនេះទេសូមប្រាកដថាត្រូវចំណាយពេលខ្លះ ដើម្បីបើកព្រះគម្ពីរអានព្រះបន្ទូលរបស់ព្រះហើយស្ដាប់សំឡេងរបស់ព្រះ។

| |
|---|
| **ចំរៀង៖** ១. មួយ ពីរ ខ្ញុំដើរតាមព្រះយេស៊ូវ ២. មានភ្នែកសម្រាប់មើលគម្ពីរ ៣. ក្នុងពេលទ្រង់ |

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ៣. ល្បែងកំសាន្ត « ឆ្លងកាត់ឧបសគ្គ »

**សម្ភារៈដែលត្រូវការ៖** កៅអី តុ ក្រមា ធុងទឹក ដុំថ្ម(តាមស្ថានភាពទីតាំង)



១. យើងបែងចែកកុមារជា ២ក្រុម។

២.ក្រុមនីមួយៗត្រូវរើសកុមារម្នាក់មក ដើម្បីរុំភ្នែករបស់គេជាមួយនឹងក្រមា

៣. យើងត្រូវយកសម្ភារៈមកដាក់ពង្រាយក្នុងថ្នាក់រៀនធ្វើជាឧបសគ្គ។

៤. ឲ្យកុមារដែលត្រូវគេចង់ភ្នែកនោះ ដើរកាត់ឧបសគ្គនៅក្នុងថ្នាក់រៀន ហើយឲ្យគេដើរត្រឡប់ទៅកន្លែងដើមវិញដោយមិនឲ្យដើរជាន់ឧបសគ្គទាំងអស់នោះ។ ក្រុមដែលបានដើរកាត់ឧបសគ្គទាំងអស់បានមុនគេ គឺជាអ្នកឈ្នះល្បែងនេះ។



៥. សូមពន្យល់ប្រាប់កុមារថា វាពិបាកខ្លាំងណាស់ក្នុងការដើរឆ្លងកាត់ឧបសគ្គទាំងអស់ ដែលយើងមិនអាចមើលឃើញ ឬគ្មាននរណាម្នាក់ជួយយើង។ ហើយក៏ដូចគ្នានឹងជីវិតយើងអីចឹងដែរ វានឹងពិបាករស់នៅណាស់បើគ្មានការដឹកនាំពីព្រះ។

## ៤. ការណែនាំមេរៀន

តើអ្នកធ្លាប់សាកល្បងអ្វីដែលថ្មីដោយគ្មានការជួយពីអ្នកដទៃដែរឬទេ? តើអ្នកអាចរៀនជិះកង់ដោយគ្មានអ្នកណាជួយដែរឬទេ? តើអ្នកអាចរៀនហែលទឹកម្នាក់ឯងដោយគ្មានអ្នកណាជួយដែលឬទេ? នៅក្នុងជីវិតគឺមានអ្វីជាច្រើនដែលយើងមិនអាចធ្វើដោយគ្មានការជួយពីអ្នកដទៃ។ ប៉ុន្តែការជួយដ៏ពិតប្រាកដ គឺយើងត្រូវការការជួយពីព្រះ។ ថ្ងៃនេះយើងនឹងរៀនអំពីរបៀប ដែលព្រះបានជួយដឹកនាំផ្លូវយើងជារៀងរាល់ថ្ងៃ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

នៅក្នុងសាច់រឿងព្រះគម្ពីរប្រជារាស្ត្ររបស់ព្រះបានភ្លេចក្នុងការថ្វាយបង្គំព្រះពិតតែមួយ។ ពួកគេបានថ្វាយបង្គំរូបព្រះដែលពួកគេបានបង្កើតឡើងចេញពីឈើ ថ្ម និងលង្ហិន។ បន្ទាប់មកស្ដេចថ្មីក៏បានកាន់កាប់អំណាចហើយគាត់ទើបតែមានអាយុ៨ឆ្នាំ! ស្ដេចនោះឈ្មោះថា យ៉ូសៀស ហើយគាត់ស្រឡាញ់ព្រះ។ យ៉ូសៀសបានឲ្យមនុស្សជាច្រើនទៅបំផ្លាញរូបព្រះទាំងអស់ដែលពួកគេបានបង្កើត។ ស្ដេចបានឲ្យមនុស្សជួសជុល និងសំអាតព្រះវិហាររបស់ព្រះដែលពីមុនបានដាក់សុទ្ធតែរូបព្រះពេញព្រះវិហារ។

បន្ទាប់មកអ្នកបម្រើរបស់ស្ដេចយ៉ូសៀសបានប្រទះឃើញព្រះគម្ពីរនៅក្នុងព្រះវិហារ។ គ្មាននរណាម្នាក់បានអានព្រះគម្ពីរជាយូរឆ្នាំមកហើយ។ គ្មាននរណាអាចចងចាំថានៅក្នុងព្រះគម្ពីរនិយាយពីអ្វីទេ។ យ៉ូសៀសរំភើបចិត្តដើម្បីរៀនអំពីព្រះនៅក្នុងព្រះគម្ពីរ។ ទ្រង់បានប្រមូលមនុស្សគ្រប់គ្នាមកជុំគ្នានៅក្នុងស្រុកយូដា ហើយទ្រង់បានអានព្រះគម្ពីរឲ្យមនុស្សគ្រប់គ្នាស្ដាប់។

យូសៀសគឺជាស្ដេចដូច្នេះទ្រង់អាចបញ្ជារឲ្យនរណាម្នាក់អានព្រះគម្ពីរក៏បាន ប៉ុន្តែយ៉ូសៀសចង់អានព្រះគម្ពីរដោយខ្លួនឯងឲ្យប្រជារាស្ត្ររបស់ទ្រង់ស្ដាប់។ នៅពេលដែលយ៉ូសៀសអានអ្វីដែលមានក្នុងព្រះគម្ពីររួច ទ្រង់បានសន្យាថានឹងដើរតាមព្រះជានិច្ច ហើយប្រជារាស្ត្ររបស់ព្រះអង្គក៏ធ្វើដូចទ្រង់ដែរ។ ទោះបីគាត់ជាស្ដេចក៏ដោយតែយ៉ូសៀសដឹងថា គាត់មិនអាចរស់នៅដោយគ្មានការដឹកនាំពីព្រះដែលគាត់បានរកឃើញនៅក្នុងព្រះគម្ពីរនោះទេ។

នៅពេលដែលមនុស្សឈប់អានព្រះគម្ពីរ ពួកគេចាប់ផ្ដើមថ្វាយបង្គំរូបព្រះ។ ពួកគេមិនមានការដឹកនាំល្អសំរាប់ជីវិតគេនោះទេ មានមនុស្សជាច្រើនបានធ្វើការជ្រើសរើសខុស។ យ៉ូសៀសគាត់ជាស្ដេចដ៏ក្មេងបំផុត គាត់ទើបតែមានអាយុ៨ឆ្នាំ ប៉ុន្តែគាត់ស្រឡាញ់ព្រះ ហើយគាត់ចង់ជ្រើសជំរើសដែលនឹងធ្វើឲ្យព្រះសប្បាយព្រះទ័យ។

តើអ្នកចង់ឲ្យព្រះដឹកនាំអ្នកនិងជួយអ្នកដើម្បីជ្រើសរើសជំរើសល្អសំរាប់ជីវិតអ្នកដែរឬទេ? ដូច្នេះអ្នកគួរតែសិក្សាព្រះគម្ពីរដូចជាយ៉ូសៀស។ ព្រះគម្ពីគឺដូចជាផែនទីដែលជួយយើង ធ្វើដំណើរឆ្ពោះទៅរកទិសដៅដែលព្រះចង់ឲ្យយើងទៅ! ព្រះមានបន្ទូលមកកាន់យើងតាមរយៈព្រះគម្ពីរ!

## ៦. សំនួរពិភាក្សា

១. តើស្ដេចពីស្រុកយូដាដែលបំផ្លាញរូបព្រះទាំងអស់នោះឈ្មោះអ្វី? *យ៉ូសៀស*

២. តើព្រះអង្គមានអាយុប៉ុន្មានពេលឡើងសោយរាជ្យ? *អាយុ ៨ឆ្នាំ*

៣. តើព្រះអង្គបានរកឃើញអ្វីខ្លះពេលកំពុងជួសជុល និងសម្អាតព្រះវិហារ? *ព្រះគម្ពីរ*

៤. ហេតុអ្វីគាត់រំភើបចិត្តពេលបានរកឃើញព្រះគម្ពីរ? *គាត់បានដឹងថាវាជាព្រះបន្ទូលរបស់ព្រះ*

៥. ហេតុអ្វីយើងគួរអានព្រះគម្ពីរ? *ព្រះមានបន្ទូលមកយើងតាមរយៈព្រះគម្ពីរ វាដូចជាផែនទីដែលបង្ហាញយើងពីទិសដៅដែលព្រះចង់ឲ្យយើងទៅ*

## ៧. ល្បែងកំសាន្ត «ឆ្លងកាត់ឧបសគ្គ »

**សម្ភារៈដែលត្រូវការ៖** មានដូចជា កៅអី តុ ក្រមា ធុងទឹក ដុំថ្ម(តាមស្ថានភាពទីតាំង)



១. យើងបែងចែកកុមារជា ២ក្រុម។
២. ក្រុមនីមួយៗត្រូវរើសកុមារម្នាក់មកដើម្បីរុំភ្នែករបស់គេជាមួយនឹងក្រមា
៣. យើងត្រូវយកសម្ភារៈ មកដាក់ពង្រាយក្នុងថ្នាក់រៀនធ្វើជាឧបសគ្គ
៤. ឲ្យកុមារដែលត្រូវគេរុំភ្នែកនោះ ដើរកាត់ឧបសគ្គនៅក្នុងថ្នាក់រៀន ហើយឲ្យកុមារនោះដើរត្រឡប់ទៅកន្លែងដើមវិញដោយមិនឲ្យដើរជាន់ឧបសគ្គទាំងអស់នោះទេ។ ប៉ុន្តែលើកនេះពួកគេនិងមានដៃគូរក្នុងការជួយប្រាប់ពួកគេ។ ក្រុមណាដែលអាចឆ្លងកាត់ឧបសគ្គនេះបានបានលឿនជាងគេ ក្រុមនោះជាអ្នកឈ្នះល្បែងនេះ។
៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់ប្រាប់កុមារថា វាគឺមានភាពងាយស្រួលក្នុងការលេងល្បែងនេះជាងមុន នៅពេលដែលយើងមានដៃគូរក្នុងការជួយយើង។ ព្រះគឺតែងតែជួយដល់យើងតាមរយៈព្រះគម្ពីរ។ សូមឲ្យយើងបានប្តេជ្ញាចិត្តក្នុងការអាន និងរៀនព្រះគម្ពីរជារៀងរាល់ថ្ងៃ។

## ៨. ខគម្ពីរចងចាំ ទំនុកដំកើង ១១៩:១០៥

## ៩. ហត្ថកម្ម «ព្រះបន្ទូលរបស់ព្រះដឹកនាំផ្លូវយើង»

**សម្ភារៈដែលត្រូវការ៖** បោះពុម្ពក្រដាសហត្ថកម្ម កូល័រ កន្ត្រៃ និងកាវ



១. សរសេរខគម្ពីរចងចាំនៅលើជើងទម្របស់ទៀន។
២. ផាត់ពណ៌ និងតុបតែងទៀននោះ។
៣. កាត់រូបទាំងអស់ចេញមក ហើយយកកាវបិត ហើយតុបតែងវាឲ្យចេញជាទៀនបង្ករ។
៤. រួចអានខគម្ពីរចងចាំជាមួយគ្នា។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

“ព្រះបន្ទូលរបស់ព្រះដឹកនាំផ្លូវយើង”




“ព្រះបន្ទូលរបស់ព្រះដឹកនាំផ្លូវយើង”

